00657392

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

F2/5/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 29 / 03 / 2011
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour Suprême

សំណុំរឿងលេខៈ ០០១/១៨-កក្កដា-២០០៧-អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 001/18-07-2007-ECCC/SC

នៅចំពោះមុខ៖

ចៅក្រម គង់ ស្រ៊ឹម ប្រធាន
ចៅក្រម Motoo NOGUCHI
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Agnieszka KLONOWIECKA-MILART
ចៅក្រម ស៊ិន រិទ្ធ
ចៅក្រម Chandra Nihal Jayasinghe
ចៅក្រម យ៉ា ណារិន

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១១

ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ

# សេចក្តីសម្រេចលើសំណើបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ សុំដាក់ភស្តុតាងបន្ថែម

00657393

០០១/១៨-កក្កដា-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

(ឯកសារលេខ **F5/2/1**)

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង

Andrew T. CAYLEY

**<u>ជនជាប់ចោទ</u>**

កាំង ហ្គេកអ៊ាវ ហៅ "ឌុច"

**<u>សហមេធាវីការពារក្តីជនជាប់ចោទ</u>**

ការ សាវុត្ថ

កង ឫទ្ធារី

**<u>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១</u>**

ទី ស្រីនណា

Karim KHAN

Alain WERNER

Brianne McGONIGLE

**<u>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម២</u>**

គង់ ពិសី

ហុង គឹមសួន

យុង ផានិត

Silke STUDZINSKY

**<u>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣</u>**

គឹម ម៉េងឃី

ម៉ុច សុវណ្ណារី

Martine JACQUIN

Annie DELAHAIE

Philippe CANONNE

Elizabeth RABESANDRATANA

Fabienne TRUSSES-NAPROUS

Christine MARTINEAU

E.C.C.C * C.E.T.C SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME

00657394

០០១/១៨-កក្កដា-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

(ឯកសារលេខ **F5/2/1**)

**អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(“**អ.វ.ត.ក**”):

**ទទួលបាន** សំណើបន្ថែមដែលបានដាក់ដោយសហមេធាវីក្រុម១ សុំដាក់ភស្តុតាងបន្ថែម (“សំណើស”)[1]។

**រំលឹកឡើងវិញ** វិធាន១០៨(៧)នៃវិធានផ្ទៃក្នុង។

**រំលឹកឡើងវិញថា** នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ អង្គជំនុំជម្រះតុលាការកំពូល តាមការផ្តួចផ្តើមគំនិតរបស់ខ្លួន ស្នើសុំការអះអាងបញ្ជាក់របស់សហមេធាវី ថាតើ ខ្លួនមានបំណងស្នើសុំដាក់ភស្តុតាងបន្ថែមដែរឬទេ[2] និងថា នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១ អង្គជំនុំជម្រះ បង្គាប់ឲ្យសហមេធាវី ព្យាយាមដាក់សំណើនេះត្រឹមថ្ងៃទី១១ ខែមីនា ឆ្នាំ២០១១[3]។

**រំលឹកឡើងវិញថា** នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១១ សហមេធាវី បានស្នើសុំដាក់ភស្តុតាងបន្ថែម[4] និងថា នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ អង្គជំនុំជម្រះតុលាការកំពូល សម្រេចទទួលយកភស្តុតាងបន្ថែម ដែលស្នើដោយសហមេធាវី[5]។

**ធ្វើការពិចារណា** លើផលប្រយោជន៍នៃយុត្តិធម៌ និងស្ថានការណ៍នៃករណីនេះ។

[1] សំណើបន្ថែមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ សុំដាក់ភស្តុតាងបន្ថែម ក្នុងការគាំទ្របណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ដាក់ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ និងជូនដំណឹង នៅថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០១១, F2/5។

[2] អ៊ីម៉ែល របស់ក្រឡាបញ្ជី នៃអង្គជំនុំជម្រះតុលាការកំពូលទៅកាន់សហេមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ១ នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១, ម៉ោង ១០:១១ ព្រឹក (ពេលវេលាភ្នំពេញ)។

[3] អ៊ីម៉ែល របស់ក្រឡាបញ្ជី នៃអង្គជំនុំជម្រះតុលាការកំពូលទៅកាន់សហេមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ១ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១, ម៉ោង ៤:៥៤ល្ងាច (ពេលវេលាភ្នំពេញ)។

[4] សំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ សំដាក់ភស្តុតាងបន្ថែមក្នុងការគាំទ្រទៅនឹងបណ្តឹងសាទុក្ខ ប្រឆាំងនឹងសាលក្រម នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១១, F2/3។

[5] សេចក្តីសម្រេចលើសំណើស្តីរបស់សហមេធាវីការពារក្តីជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ២ និង[illegible] សុំដាក់ភស្តុតាងបន្ថែម ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ F2/4។

**កត់សំគាល់ឃើញថា** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលអនុញ្ញាតលើសំណើសុំដាក់ភស្តុតាងបន្ថែម មិនមានផលប៉ះពាល់ដល់ការសម្រេចលើបណ្តឹងសាទុក្ខអំពីទម្ងន់នៃភស្តុតាងបន្ថែមឡើយ។

**យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលសម្រេច៖**

ទទួលយកសំណើសុំដាក់ភស្តុតាងបន្ថែមដូចខាងក្រោម:

| ឈ្មោះឯកសារ | លេខឯកសារ | **KH ERN** | **EN ERN** |
|---|---|---|---|
| សេចក្តីថ្លែងរបស់សាក្សី | F2/5.2.1 | 00657012-00657013 | 00657011-00657011 |
| វិញ្ញាបនប័ត្រ | F2/5.2.1.1 | 00657014-00657014 | គ្មាន |
| សេចក្តីថ្លែងរបស់សាក្សី | F2/5.2.2 | 00657016-00657018 | 00657015-00657015 |
| លិខិតឆ្លងដែន | F2/5.2.2.1 | 00657019-00657019 | គ្មាន |

**រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១១**

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

SUPREME COURT CHAMBER * E.C.C.C * C.E.T.C * CHAMBRE DE LA COUR SUPREME

**គង់ ស្រីម**